**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រុមហ៊ុន ហ្គ្រេន ធ្វីន អ៊ិនធើណេសិនណាល
(ខេមបូឌា) តីអិលស៊ី

*រាជធានីភ្នំពេញ ថ្ងៃទី ០២ ខែឧសភា ឆ្នាំ២០២៣*

# សេចក្តីណែនាំ

## ពីការចុះឈ្មោះ ចុះវត្តមាន និងការតែងតាំងអាណត្តិគាហក: (អ្នកតំណាង) ដើម្បីចូលរួមមហាសន្និបាតភាគហ៊ុនិក លើកទី៩ របស់ ក្រុមហ៊ុន ហ្គ្រេន ធ្វីន អ៊ិនធើណេសិនណាល (ខេមបូឌា) តីអិលស៊ី

ក្រុមហ៊ុន ហ្គ្រេន ធ្វីន អ៊ិនធើណេសិនណាល (ខេមបូឌា) តីអិលស៊ី (“**ក្រុមហ៊ុន**” ឬ “**ហ្គ្រេន ធ្វីន**” ឬ “**ហ.ធ.អ**”) ជាក្រុមហ៊ុនឯកជនដំបូងបង្អស់ដែលចុះបញ្ជីលក់មូលបត្រនៅផ្សារមូលបត្រកម្ពុជា (“**ផ.ម.ក**”) មានកិត្តិយសសូមជម្រាបជូនដំណឹងដល់ភាគហ៊ុនិកកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតរបស់ក្រុមហ៊ុន ហ្គ្រេន ធ្វីន និងសាធារណៈជនទាំងអស់ មេត្តាជ្រាបថា ៖ ក្រុមហ៊ុននឹងចាប់ផ្តើមទទួលការចុះឈ្មោះចូលរួមមហាសន្និបាតភាគហ៊ុនិក លើកទី៩ របស់ក្រុមហ៊ុន ចាប់ពីថ្ងៃទី០៩ ដល់ ថ្ងៃទី១២ ខែឧសភា ឆ្នាំ២០២៣ នេះតទៅ។ ភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោត ដែលមានរាយនាមក្នុងបញ្ជីភាគហ៊ុនិកផ្លូវការរបស់ក្រុមហ៊ុន ហ្គ្រេន ធ្វីន នៅថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០២៣ មានសិទ្ធចូលរួមមហាសន្និបាតភាគហ៊ុនិក លើកទី៩ របស់ក្រុមហ៊ុន ដែលនឹងប្រព្រឹត្តិទៅនៅថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០២៣ បានលុះត្រាតែ ៖

### ក- ការចុះឈ្មោះចូលរួម

ភាគហ៊ុនិកអាចចុះឈ្មោះចូលរួមមហាសន្និបាតភាគហ៊ុនិក លើកទី៩ ជាមួយធនាគារ អេស៊ីលីដា តីអិលស៊ី ដែលជាភ្នាក់ងារចុះបញ្ជីផ្ទេរមូលបត្រ និងទូទាត់ជំនួសរបស់ក្រុមហ៊ុន ហ្គ្រេន ធ្វីន ដែលមានទីតាំងនៅអាគារលេខ៦១ មហាវិថីព្រះមុនីវង្ស សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ រៀងរាល់ថ្ងៃធ្វើការ ចាប់ពីថ្ងៃទី០៩ ដល់ ថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០២៣ ចាប់ពីម៉ោង ០៨: ០០ នាទី ព្រឹក ដល់ ម៉ោង ០៥:០០ នាទី រសៀល។

ភាគហ៊ុនិកអាចចុះឈ្មោះចូលរួមមហាសន្និបាតភាគហ៊ុនិក លើកទី៩ ជាមួយ ធនាគារ អេស៊ីលីដា តីអិលស៊ី ដែលជាភ្នាក់ងារផ្ទេរមូលបត្រ និងទូទាត់ជំនួសរបស់ក្រុមហ៊ុនបាន តាមរយៈអ៊ីម៉ែល ឬមធ្យោបាយណាមួយក៏បាន។ ភាគហ៊ុនិក អាចមកធនាគារ អេស៊ីលីដា តីអិលស៊ី តាមអាសយដ្ឋានខាងលើ ដោយផ្ទាល់ ឬចាត់តាំងអាណត្តិគាហក: (អ្នកតំណាង) ដើម្បីទទួលបានលិខិតអញ្ជើញចូលរួមមហាសន្និបាត លើកទី៩ នេះ។

ក្នុងករណី ភាគហ៊ុនិកបានចុះឈ្មោះចូលរួមមហាសន្និបាតភាគហ៊ុនិក លើកទី៩ តែពុំបានអញ្ជើញមកទទួលបានលិខិតអញ្ជើញចូលរួមមហាសន្និបាតភាគហ៊ុនិក លើកទី៩ នេះ ភាគហ៊ុនិក នៅតែមានសិទ្ធិចូលរួមមហាសន្និបាតភាគហ៊ុនិក លើកទី៨ នេះបាន។

ភាគហ៊ុនិក ត្រូវបាត់បង់សិទ្ធិក្នុងការចូលរួមមហាសន្និបាតភាគហ៊ុនិក លើកទី៩ ប្រសិនបើ ភាគហ៊ុនិក ឬអាណាព្យាបាល: មិនបានចុះឈ្មោះតាមពេលកំណត់ខាងលើ និងមិនបានគោរពតាមសេចក្តីណែនាំនេះ។

ក្នុងពេលចុះឈ្មោះចូលរួម ភាគហ៊ុនិក ឬអាណាព្យាបាល: (អ្នកតំណាង) ទទួលបាននូវលិខិតអញ្ជើញចូលរួមមហាសន្និបាតភាគហ៊ុនិក លើកទី៩ របស់ក្រុមហ៊ុន ហ្គ្រេន ធ្វីន។

***សម្គាល់៖ លិខិតអញ្ជើញចូលរួមមហាសន្និបាតភាគហ៊ុនិក មិនមាន ចែកជូនទៀតទេ។***

**ខ- ការចុះវត្តមាន**

មហាសន្និបាតភាគហ៊ុនិក លើកទី៩ របស់ក្រុមហ៊ុន នឹងប្រារព្ធនៅទីស្នាក់ការក្រុមហ៊ុន លើកលែងតែ មានការចាំបាច់ណាមួយពីការផ្លាស់ប្តូរទីតាំងប្រារព្ធមហាសន្និបាតភាគហ៊ុនិក ក្រុមហ៊ុននឹងជូនដំណឹងជូនភាគហ៊ុនិកជាមុន។

- កាលបរិច្ឆេទមហាសន្និបាតភាគហ៊ុនិក លើកទី៩ ៖ ថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០២៣
- វេលាម៉ោង ៖ ចាប់ពីម៉ោង ០៨: ០០ ព្រឹក ដល់ម៉ោង ១១: ៣០ ថ្ងៃត្រង់
- ការចុះវត្តមាន ៖ ចាប់ពីម៉ោង ០៨: ០០ ព្រឹក ដល់ម៉ោង ០៩: ០០ ព្រឹក

ការខកខានពុំបានចុះវត្តមានតាមការកំណត់ខាងលើ នឹងបាត់បង់សិទ្ធិក្នុងការចូលរួមមហាសន្និបាតភាគហ៊ុនិក លើកទី៩ នេះ។

ភាគហ៊ុនិកដែលចូលរួមក្នុងមហាសន្និបាតនេះ ត្រូវយកមកជាមួយនូវលិខិតអញ្ជើញចូលរួមមហាសន្និបាត លើកទី៩ (ប្រសិនមាន) ដែលទទួលបានក្នុងពេលចុះឈ្មោះចូលរួម កាលពីថ្ងៃទី០៩ ដល់ ថ្ងៃទី១២ ខែឧសភា ឆ្នាំ២០២៣ នៅធនាគារអេស៊ីលីដា ភីអិលស៊ី និងអត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែន។ ករណី ភាគហ៊ុនិកប្រគល់សិទ្ធិឲ្យអ្នកតំណាងមកចូលរួមជំនួស ត្រូវភ្ជាប់ជាមួយនូវលិខិតផ្ទេរសិទ្ធិ ដែលមានហត្ថលេខារបស់ភាគហ៊ុនិក និងអាណាព្យាបាល: (អ្នកតំណាង) "***លិខិតតែងតាំងអាណាព្យាបាល: (អ្នកតំណាង)*** " ទៅតាមទម្រង់ដែលកំណត់ដោយក្រុមហ៊ុន ហ្គ្រេន ធ្វីន។ អាណាព្យាបាល: (អ្នកតំណាង) ត្រូវយកមកជាមួយផងដែរនូវអត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែនរបស់ខ្លួន។

**គ- ការតែងតាំងអាណាព្យាបាល:(អ្នកតំណាង)**

ក្នុងករណី ភាគហ៊ុនិកចាត់អ្នកតំណាងមកចុះឈ្មោះចូលរួមជំនួសក្នុងមហាសន្និបាតភាគហ៊ុនិក លើកទី៩ របស់ក្រុមហ៊ុន ភាគហ៊ុនិកត្រូវតែងតាំងអាណាព្យាបាល: (អ្នកតំណាង)។ អាណាព្យាបាល: (អ្នកតំណាង) ត្រូវដាក់លិខិតតែងអាណាព្យាបាល: (អ្នកតំណាង) ដោយភាគហ៊ុនិក ជូនក្រុមហ៊ុន នៅពេលចុះវត្តមាននៅកន្លែងប្រារព្ធពិធី ដើម្បីចូលរួមមហាសន្និបាតភាគហ៊ុនិក លើកទី៩ នេះ ។

ក្នុងករណីភាគហ៊ុនិកចាត់អ្នកតំណាងមកចូលរួមជំនួសក្នុងមហាសន្និបាតភាគហ៊ុនិក លើកទី៩ របស់ក្រុមហ៊ុន ភាគហ៊ុនិកត្រូវតែងតាំងអាណត្តិគាហក: (អ្នកតំណាង) ទៅតាមទម្រង់ "***លិខិតតែងតាំង អាណត្តិគាហក: (អ្នកតំណាង)***" ដែលកំណត់ដោយក្រុមហ៊ុន។

ភាគហ៊ុនិកម្នាក់អាចតែងតាំងអាណត្តិគាហក: (អ្នកតំណាង) តែម្នាក់ប៉ុណ្ណោះ។ ភាគហ៊ុនិកច្រើននាក់ អាចតែងតាំង អាណត្តិគាហក: (អ្នកតំណាង) រួមគ្នាបាន។

ទម្រង់ "***លិខិតតែងតាំង អាណត្តិគាហក: (អ្នកតំណាង)***" មាន ពីរប្រភេទ គឺ សម្រាប់ភាគហ៊ុនិកជា នីតិបុគ្គល និង ភាគហ៊ុនិកជា រូបវន្តបុគ្គល។

ដើម្បីផ្តល់ភាពងាយស្រួលដល់ភាគហ៊ុនិក ទម្រង់លិខិតតែងតាំងអាណត្តិគាហក: (អ្នកតំណាង) ត្រូវបានរៀបរៀងជា ពីរ ភាសា គឺ ភាសាខ្មែរ និងភាសាអង់គ្លេស។ ភាគហ៊ុនិក អាចជ្រើសរើសទម្រង់លិខិតជាភាសាណាមួយក៏បាន។

សម្រាប់ព័ត៌មានលម្អិតពីការចុះឈ្មោះចូលរួមមហាសន្និបាតភាគហ៊ុនិក លើកទី៩ ភាគហ៊ុនិក អាចទាក់ទងមក លោកស្រី **ឃឹម រស្មី** តាមរយៈទូរស័ព្ទលេខ (៨៥៥)១២ ២២២ ៥០៨ ឬ តាមអ៊ីម៉ែល qmig.ac08@qmico.com ឬតាមរយៈធនាគារ អេស៊ីលីដា ភីអិលស៊ី ជាភ្នាក់ងារចុះបញ្ជីផ្ទេរមូលបត្រ និងទូទាត់ជំនួសរបស់ក្រុមហ៊ុន ហ្គ្រេន ធ្វីន ដូចខាងក្រោម ៖

- អាសយដ្ឋាន: អាគារលេខ៦១ មហាវិថីព្រះមុនីវង្ស សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ
- ទូរស័ព្ទ: (៨៥៥)១៥-៩០០ ៥៣៨
- អ៊ីម៉ែល: huot.sophy@acledabank.com.kh
- ទូរសារ: (៨៥៥)១៥ ៨០០ ៦៦៣
- អ៊ីម៉ែល: ken.rithputhea@acledabank.com.kh
- ទូរស័ព្ទដៃ: (៨៥៥)៦១-២៨៧ ៧៦៦
- អ៊ីម៉ែល: op.rtp@acledabank.com.kh

ព្រះរាជាណាចក្រកម្ពុជា ក្រុមហ៊ុន គ្រេន ធ្វីន អ៊ិនធើណេសិនណាល (ខេមបូឌា) ធីអិលស៊ី GRAND TWINS INTERNATIONAL CAMBODIA PLC KINGDOM OF CAMBODIA

**ក្រុមហ៊ុន ហ្គ្រេន ធ្វីន អ៊ិនធើណេសិនណាល (ខេមបូឌា) ធីអិលស៊ី**